ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព និងការធ្វើអនុប្បយោគ លើផ្ទៃដីទំហំ ៩ ៩៦៨ (ប្រាំបួនពាន់ប្រាំបួនរយហុកសិបប្រាំបី)ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រស្រុកបូទុមសាគរ ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ. បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ជាតំបន់គ្រប់គ្រង លើផ្ទៃដីទំហំ ៩ ៩៦៨ (ប្រាំបួនពាន់ប្រាំបួនរយហុកសិបប្រាំបី) ហិកតា ក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រស្រុកបូទុមសាគរ ខេត្តកោះកុង ទៅជាតំបន់ប្រើប្រាស់ដោយ

ចីរភាព ដូចមានផែនទី និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ដើម្បីបន្តរៀបចំបំពេញបែបបទនីតិវិធីជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២ .-**

ត្រូវបានធ្វើអនុប្បយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋលើផ្ទៃដីទំហំ ៩ ៩៦៨ (ប្រាំបួនពាន់ប្រាំបួនរយហុកសិបប្រាំបី) ហិកតា ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្រោមលក្ខខណ្ឌជួលឱ្យក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប សម្រាប់គម្រោងវិនិយោគ ដែលស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថានជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកោះកុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃពុធ ៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




| Id | X | Y | Id | X | Y |
|---|---|---|---|---|---|
| 1 | 315974.604 | 1229439.267 | 33 | 308498.409 | 1217663.333 |
| 2 | 320685.431 | 1227808.233 | 34 | 309104.844 | 1218060.696 |
| 3 | 320604.807 | 1227759.381 | 35 | 309353.173 | 1218347.824 |
| 4 | 320535.464 | 1227745.814 | 36 | 309680.423 | 1218661.343 |
| 5 | 320426.928 | 1227688.531 | 37 | 310063.428 | 1218852.345 |
| 6 | 320426.928 | 1227572.457 | 38 | 310011.427 | 1219148.348 |
| 7 | 320377.182 | 1227478.995 | 39 | 309962.427 | 1219272.349 |
| 8 | 320381.318 | 1227417.273 | 40 | 309966.427 | 1219300.350 |
| 9 | 320176.054 | 1227237.124 | 41 | 310112.429 | 1219406.351 |
| 10 | 320131.186 | 1227032.166 | 42 | 310275.431 | 1219442.351 |
| 11 | 320139.118 | 1226783.466 | 43 | 310448.433 | 1219599.353 |
| 12 | 320067.347 | 1226591.599 | 44 | 310318.432 | 1219891.356 |
| 13 | 319493.700 | 1226325.790 | 45 | 310294.431 | 1219940.357 |
| 14 | 318612.529 | 1225139.150 | 46 | 310324.432 | 1220121.359 |
| 15 | 318383.193 | 1224890.830 | 47 | 310407.433 | 1220300.361 |
| 16 | 317053.244 | 1223949.027 | 48 | 310378.433 | 1220370.361 |
| 17 | 316074.469 | 1223544.202 | 49 | 310310.432 | 1220400.362 |
| 18 | 315015.806 | 1223107.020 | 50 | 310274.029 | 1220394.378 |
| 19 | 313793.469 | 1222604.715 | 51 | 309082.196 | 1222490.310 |
| 20 | 313100.684 | 1222016.655 | 52 | 308901.800 | 1223321.914 |
| 21 | 312724.597 | 1221344.461 | 53 | 308517.211 | 1223787.046 |
| 22 | 314166.303 | 1221398.523 | 54 | 308650.762 | 1224040.040 |
| 23 | 312766.843 | 1220628.317 | 55 | 309309.215 | 1225669.877 |
| 24 | 312452.849 | 1217758.239 | 56 | 310346.477 | 1227459.371 |
| 25 | 311208.746 | 1216128.018 | 57 | 310504.419 | 1228808.536 |
| 26 | 309743.613 | 1215486.402 | 58 | 310640.299 | 1229311.687 |
| 27 | 307398.112 | 1215742.480 | 59 | 311691.346 | 1233107.354 |
| 28 | 306183.060 | 1218043.598 | 60 | 311545.825 | 1234099.543 |
| 29 | 306603.507 | 1218017.683 | 61 | 312136.667 | 1234678.377 |
| 30 | 307028.088 | 1217865.269 | 62 | 312601.298 | 1234811.961 |
| 31 | 307474.443 | 1217680.195 | 63 | 312599.000 | 1234802.000 |
| 32 | 307962.403 | 1217634.333 | 64 | 315974.604 | 1229439.267 |